កាលនាង លូ ហ្ស៊ី ចួបជាមួយ លីវ ប៉ាង(អ្នកសាងរាជវង្សហាន) នាងទើបតែមានវ័យ១៩ឆ្នាំ ហើយបានភៀសខ្លួនពីស្រុកកំណើតនៅខេត្តសានទុង ក្នុងឆ្នាំ២៤១ មុនគ.ស។

ឪពុកនាងឈ្មោះលូន វ៉ាន ជាមនុស្សមានប្រាក់ហើយក្រអឺតក្រទម មានសត្រូវច្រើន។ ពេលភៀសខ្លួននេះគឺ មកតែពីនាងត្រូវរត់គេចចេញពីការរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកមានអំណាច ដែលនាងមិនព្រមយកមកជាស្វាមី ហើយត្រូវបង្ខំចិត្តមកដល់ទីប្រជុំជន ហ្សុងយ៉ាង។

នៅទីនោះ មេសន្តិសុខថ្នាក់ភូមិគឺ លីវ ប៉ាង បានចេញមុខជួយសង្គ្រោះឪពុករបស់នាងពីសត្រូវដែលតាមយាយីរហូតដល់ លី ហ្ស៊ី បានស្ម័គ្រចិត្តរៀបការជាមួយដើម្បីផ្តល់ការធានាសន្តិសុខដល់គ្រួសាររបស់នាង។

ក្រោយអាពាហ៍ពិពាហ៍ជាមួយលីវប៉ាងដែលក្រលំបាក នាងបានព្រមផ្លាស់មកនៅបម្រើឪពុកម្តាយក្មេកនិងបង្កើតកូនស្រីច្បងឱ្យលីវប៉ាង ក្រោយមកកូនប្រុសមួយទៀត លីវយីងដែលក្រោយមកសោយរាជ្យជា អធិរាជ Hui នៃរជ្ជកាលហានជំនាន់ទីពីរ។

គ្រប់យ៉ាងនៅត្រកូលលីវ មិនបានចាប់ផ្តើមល្អទេ សម្រាប់លូ ហ្ស៊ី។ សម័យកាលដ៏ច្របូកច្របល់ជាមួយនឹងការបះបោរដ៏ខ្លាំងក្លាប្រឆាំងនឹងអធិរាជឈីង បានបណ្តាលឱ្យប្តីនាង គឺលីវប៉ាងដែលកំពុងកេណ្ឌទ័ពមួយក្រុមទៅកាន់ទីរួមខេត្ត ត្រូវក្លាយជាមានទោសដោយសារបណ្តោយឱ្យអ្នកទោសជិតពាក់កណ្តាលបានរត់គេចរួច។

វាជាបទល្មើសធំមួយក្នុងការបាត់បង់អ្នកទោស ដូច្នេះលីវប៉ាងមិនព្រមវិលទៅទទួលទោសដែរ មានតែសម្រេចចិត្តចូលរួមជាមួយកងទ័ពឧទ្ទាម ហើយបានក្លាយជាមេក្រុមភ្លាម។

ចៅក្រមក្នុងស្រុកកំណើត បានចេញប្រកាសតាមចាប់លីវប៉ាង និងចាប់ខ្លួនឪពុកម្តាយនិងប្រពន្ធកូននៅផ្ទះគឺ Lu Zhi ពីបទពាក់ព័ន្ធគ្រួសារជាមួយមេដឹកនាំឧទ្ទាម។

សំណាងល្អ មេឆ្មាំគុក គឺជាមិត្តភក្តិចាស់ធ្លាប់ទទួលគុណពីលីវប៉ាង ក៏បានលបលាក់ដោះលែងពួកគេជាសម្ងាត់។

ពេលទៅចូលស៊ប់នឹងសង្គ្រាម លីវប៉ាងបានផ្តាំទុកឪពុកម្តាយនិងប្រពន្ធឱ្យស្ថិតក្នុងការមើលថែរបស់មិត្តភក្តិម្នាក់ឈ្មោះលោក Shen Yiji ។ ជាអកុសល ពួកគេត្រូវបានចាប់ខ្លួន ដោយមេទ័ពប្រជែងនៃនគរឈូ គឺ Xiang Yu ដែលជាស្តេចត្រាញ់នៃតំបន់ Chu ខាងលិច។

ក្នុងរយៈពេលបីឆ្នាំក្រោយឈ្នះឈើង លីវប៉ាងបានក្លាយជាស្តេចហាន តែមិនទាន់វាតទឹកដីបានទាំងស្រុងទេ។ គូប្រជែងដ៏ធំបំផុត គឺ Xian Yu នៅមានប្រពន្ធនិងឪពុកម្តាយខ្លួនក្នុងដៃ។ ពេលក្រុមលីវប៉ាងខ្លាំងជាង មេទ័ពXiang Yu បានយកគ្រួសារគេមកគំរាមថា នឹងចម្អិនជាស៊ុប ប្រសិនបើលីវប៉ាង មិនចុះចាញ់។

ជាការភ្ញាក់ផ្អើលខ្លាំងដែលលីវប៉ាងបានសរសេរមកវិញថា មិនត្រឹមតែបដិសេធប៉ុណ្ណោះទេ គាត់ថែមទាំងបានសុំ Xiang Yu ចែកស៊ុបមួយចានមកហូបទៀតផង។

ជាសំណាងល្អ ស្តេចត្រាញ់ឈ្មួខាងលិចមិនបានធ្វើរឿងចម្អិននេះ។ នៅក្រោយសង្គ្រាមចប់ព្រោះលីវប៉ាងអាចវាយសន្ធប់ បំបាក់កងទ័ព Chu ហើយ Xiang Yu បានធ្វើអត្តឃាត លីវប៉ាងបានបន្តបង្កើតអាណាចក្រហាន ដោយមានប្រពន្ធដើម នាងលូហ្ស៊ី ជារាជនីទីមួយនៃប្រទេសចិន។ មិត្តភក្តិខ្លួនគឺ Shen Yiji ជារដ្ឋមន្ត្រីជាន់ខ្ពស់។

ដំបូងប្រវត្តិសរសេរថា លូ ហ្ស៊ី គឺជាស្ត្រីដែលមានចិត្តល្អនិងសុភាព តែសេចក្តីព្រាត់ប្រាសវេទនាការធ្វើទុក្ខអត់ឃ្លាននិងទារុណកម្មរាប់ឆ្នាំ រួមទាំងបីឆ្នាំក្នុងនាមជាឈ្លើយសឹក បានធ្វើឱ្យ Lu Zhi រងរបួសសតិអារម្មណ៍។ បទពិសោធន៍នេះបានបង្រៀននាងពីការពិតដ៏អាក្រក់នៃជីវិត ហើយបានធ្វើឱ្យនាងក្លាយមកជាស្ត្រីរឹងរូសនិងជូរចត់ ជាមួយនឹងគំនិតសង្ស័យដ៏ស្មុគស្មាញដ៏គួរឱ្យភ័យខ្លាច។

ស្ថានភាពផ្លូវចិត្តរបស់នាងកាន់តែតានតឹង ពេលមកដល់ក្បែរប្តី ឃើញវត្តមានរបស់ Lady ឈី ដ៏ស្រស់ស្អាត ដែលបានថ្នាក់ថ្នមរក្សាក្បែរ Liu Bang ខណៈអវត្តមាន Lu Zhi ហើយប្រពន្ធដើមកំពុងទទួលនូវការរងទុក្ខអត់ឃ្លាន ការរំលោភបំពានក្នុងនាមជាអ្នកទោសនៃកងទ័ព Chu ។

ទោះជាយ៉ាងណាក៏ដោយ Lu Zhi នៅតែស្មោះត្រង់និងគាំទ្រស្វាមីរបស់នាង ប៉ុន្តែបទពិសោធន៍ព្រហ្មទណ្ឌបានធ្វើឱ្យរាជនីថ្មីក្លាយជាស្ត្រីដែលមានគំនិតជ្រៅសន្លឹម។

ដោយសារនោះជាសម័យកាល ដែលលីវប៉ាងចេញតស៊ូប្រឆាំងរាជការឈើងដ៏ពុករលួយផ្តាច់ការគេបានព្រាត់ពីប្រពន្ធមួយរយៈហើយបានស្គាល់គ្នាជាមួយសិល្បការិនីលេងភ្លេងម្នាក់តាមផ្លូវធ្វើសឹកនាងជាម៉េម៉ាយប្តីស្លាប់ ឈ្មោះឈី។

ឈី កើតនៅស្រុកឌីងតាវ ខេត្តសានទុង ដែលមានកាយសម្បទា សម្បុរស្បែកនិងសម្រស់ស្អាតជាខ្លាំង។ ពេលលីវប៉ាងចួបនាងតាមផ្លូវ នាងកំពុងរត់គេចពីចម្បាំង គ្មានផ្ទះសម្បែង និងគ្មានញាតិទេ។ លីវបានសួរនាងថា «ផ្លូវទៅមុខវែងអន្លាយ នាងព្រមធ្វើជាប្រពន្ធចុង និងទៅជាមួយបុរសទ័ពព្រៃ

ម្នាក់នេះដែរ?» នាងបានសម្លឹងលីវពីលើដល់ក្រោមក៏ចាប់អារម្មណ៍ថាគាត់ជាបុរសអង់អាច អាចពឹងពាក់បានទៅថ្ងៃមុខ។

ចាប់ពីពេលនោះមក នាងបានក្លាយជាមនុស្សស្រីដែលនៅកៀកនឹងលីវប៉ាងជាងគេ រហូតដល់សង្គ្រាមចប់ហើយបានបង្កើតបានកូនប្រុសម្នាក់គឺ លីវ រូយី Liu Ruyi ។ ប្រវត្តិសាស្ត្រសរសេរថា លើសពីភាពជាភរិយា ឈីក៏មានទេពកោសល្យពិសេសមួយ គឺការរាំនិងកេះភ្លេង។ មិនត្រឹមតែស្អាតស្រស់ថ្លាទេ រាល់ពេលឈីរាំយ៉ាងល្វត់ល្វៃ បានធ្វើឱ្យលីវប៉ាងកាន់តែលង់ស្នេហ៍ ទោះនាងជាស្ត្រីមិនយល់នយោបាយ ស្លូត និងមិននិយាយច្រើន តែយល់ពីវិធីធ្វើឱ្យស្វាមីសប្បាយចិត្ត។ រាល់ពេលលីវប៉ាងពិបាកចិត្តក្នុងចិត្ត នាងគ្រាន់តែរាំមួយបទ គេក៏អាចបំបាត់កង្វល់ទាំងអស់បានភ្លាម ទាំងនេះជាកម្លាំងចិត្តដែលធ្វើឱ្យលីវប៉ាងចង់តែនៅជិតនិងស្រលាញ់នាងតែម្នាក់ប៉ុណ្ណោះ។ ដោយសារតែនាងត្រូវបានលីវប៉ាងស្រលាញ់ថ្នាក់ថ្នមខ្លាំងហើយល្បីសុសសាយ។

មានចំណារថា មានពេលមួយ មេទ័ពស៊ាងយូនៃនគរឈូបានចាប់ប្រពន្ធខ្លួន លូហ្សុីនិងកូនៗទៅជំរំទ័ពក៏លីវប៉ាង រវល់ងប់ងុលភរិយាចុងមិនអើពើនឹងដំណឹងនេះឡើយ។

បន្ទាប់ពីបានភៀសខ្លួនត្រលប់មកដល់ជំរុំខាងប្ដីវិញ លូហ្សុីបានរកឃើញថា មានស្ត្រីថ្មីនៅក្បែរស្វាមីខ្លួន។ ចាប់ពីពេលនោះមក ចរិតនិងនិស្ស័យចាស់របស់លូហ្សុីចាប់ផ្ដើមផ្លាស់ប្ដូរ។ ពីភរិយាដ៏សប្បុរសនិងគុណធម៌ ក្លាយជាមនុស្សរសើប ងាយគិតនិងសង្ស័យជានិច្ច។

ព្រោះតែនាងឈីនៅក្មេងជាងលូហ្សុី ហើយមើលស្លូតជាង ដូច្នេះតែងឈ្នះក្ដីស្រលាញ់ពីប្ដីជាងប្រពន្ធដើម។ ជាមួយនោះ មានមនុស្សជុំវិញនាងបានបង្រៀននិងបញ្ចុះបញ្ចូលនាងឱ្យអង្វរប្ដីឱ្យតែងតាំងកូនប្រុសតូច រូយីឡើងជារាជទាយាទ ហើយលុបចោលតំណែងជាមហាក្សត្រីរបស់លូហ្សុី។

ជារឿយៗ លូហ្សុីតែងតែរងទឹកភ្នែកក្រោយពីបានដឹងដំណឹងនេះ។ ក្រៅពីនាងមានអារម្មណ៍ខកចិត្តជាខ្លាំងចំពោះប្រពន្ធចុងឈ្មោះឈី ដែលមានពិសក្រោមភាពស្ងប់ស្ងាត់ លូហ្សុីកាន់តែខឹង កាន់តែចាស់លែងស្អាត ឃ្លាតឆ្ងាយពីប្ដីឡើង។

ដោយសារឈី ត្រូវបានគេពេញចិត្ត ជាញឹកញាប់មានឱកាសផ្ដុំខ្មើយនៅចំពោះមុខលីវប៉ាងដោយនិយាយអាក្រក់អំពីប្រពន្ធដើម ជាញឹកញាប់ ទោះណាជាប្ដីនៅនៅតែរក្សាភាពស្ងប់ស្ងាត់ និងមិនដែលយល់ព្រមជឿ ក៏ឈីមិនបោះបង់ការព្យាយាមឡើយ។

ទំនាស់រវាងប្រពន្ធចុងនិងដើម នៅតែបន្តធំដូចរងើកភ្លើង ម្ល៉ោះហើយឈីសង្ស័យថា ប្រសិនខ្លួនមិនជោគជ័យហើយកូនប្រុសភរិយាដើមបានឡើងស្នងអំណាច នាងនឹងកូនច្បាស់ជាមានបញ្ហា។ ជារឿយៗ ឈីបានល្បួងលួងកូនប្រុសរបស់ប្រពន្ធដើម គឺលីវយីងថា តួនាទីឯងជាបងប្រុស ជានិច្ចជាកាលត្រូវមើលថែប្អូន។

ឈីដូចជាមានទំនោរគិតទុកមកជាមុនថា មុននិងក្រោយលូហ្ស៊ីដែលជាប្រពន្ធដើម នឹងរកឱកាសធ្វើទុក្ខនាង ឬកូនប្រុសរបស់នាង ព្រោះសម្អប់។

បន្ទាប់ពីការឡើងសោយរាជ្យរបស់លីវប៉ាង ជាអធិរាជហានទីមួយហើយ អំណាចលូហ្ស៊ីក៏បានបន្តគ្រប់ដណ្តប់លើឆាកនយោបាយ ក្នុងឈ្មោះថា មហាក្សត្រីលូ Empress Lu ។ តែបញ្ហាសំខាន់មួយថ្មី ដែលយាយីអំណាចនេះ គឺលីវប៉ាងតែងមិនសប្បាយចិត្តនឹងចរិតទន់ជ្រាយនៃកូនប្រុសច្បងគឺលីវយីងសោះ។

រាជនីលូ បានតម្កើងខ្លួនឯងយ៉ាងឱឡារិកថា ជាស្ត្រីទីមួយដែលមានសមត្ថភាពគ្រប់គ្រងខ្ពស់ ជារឿយៗលូកដៃជួយទទួលបន្ទុកកិច្ចការរដ្ឋនៅរាជធានីឆាងអាន Chang'an រាល់ពេលណាដែលស្វាមីរបស់នាងនៅឆ្ងាយ ជាប់រវល់ទៅកម្ចាត់ពួកងើបបះបោរ។

គោលនយោបាយរបស់ក្សត្រីលូត្រូវបានគេមើលឃើញថា មានឥទ្ធិពលវិជ្ជមានទៅលើប្រទេសមួយនេះ ខណៈដែលបានកែលម្អលក្ខខណ្ឌសម្រាប់ជនក្រីក្រ សាងសង់ឡើងវិញនៃមហាកំផែងការពារ និងការបង្កើនប្រាក់ចំណូលរបស់រដ្ឋ។ ក្នុងសវនាការ នាងត្រូវបានគោរពដោយរដ្ឋមន្ត្រីជាច្រើនរបស់អធិរាជចំពោះសមត្ថភាពរបស់នាងនិងគុណធម៌ កាលពីនាងរៀបការដំបូង បានចិញ្ចឹមឪពុកម្តាយក្មេក និងថែទាំកូនជំនួសប្តីដែលតែងតែរត់ភៀសទៅឆ្ងាយ លេងល្បែង ផឹកស្រាមានស្រីច្រើន។

ចំណេរក្រោយមក ការភ័យខ្លាចចំពោះការបាត់បង់អំណាច បានរំលេចភាពឃោរឃៅរបស់នាង។ លូហ្ស៊ី ដែលហៅថារាជនីលូ បាននៅពីក្រោយផែនការសម្លាប់ហានស៊ីង Han xin និងប៉េងយូអ៊ី Peng Yui ផងដែរ។ ហានស៊ីងនិងប៉េងយូអ៊ី គឺជាឧត្តមមន្ត្រីកៀកស្មាបានតាមជួយលីវប៉ាងរហូតទទួលបានអំណាចតាំងពីសម័យតស៊ូមក។

ហានស៊ីងដែលមានគំនិតបញ្ញាទ័ពវាងវៃ ក្រោយដែលលើងប៉ាងឈ្នះនគរឈើង គេក៏បានក្លាយជាអភិជនខ្ពស់ដែលមានឥស្សរៈខ្ពស់ កាន់សេនាធិការទ័ពធំជាងគេនៅក្នុងប្រទេស។ គេមើលទៅ មានកិត្តិនាមដូចជាវីរបុរសនៅដើមរាជវង្ស សឹងថាគ្របពីលើកិត្តិនាមអធិរាជប្តីប្រពន្ធទៅទៀតផង។

នេះជាការមួយមិនឱ្យមនុស្សដូចរាជនីលូសប្បាយចិត្តទេ។

ដោយមើលឃើញថា Han Xin គឺជាមនុស្សពិសេសម្នាក់ ក្នុងចំណោមអ្នកមានទេពកោសល្យដ៏កម្រក្នុងប្រវត្តិសាស្ត្រចិន ដែលអាចផ្លាស់ប្តូរទិសដៅនៃប្រវត្តិសាស្ត្របានទាំងសមត្ថភាពយុទ្ធសាស្ត្រ និងសង្គ្រាម អាចដឹកនាំកងទ័ពដោយឯករាជ្យពង្រីកកិត្តិសព្ទមនោគមវិទ្យាយ៉ាងរហ័ស អាចគ្រប់គ្រងភស្តុភាដែលនៅក្នុងនគរហាន ពិតជាគ្មានមេទ័ពឬមន្ត្រីណាអាចផ្ទឹមស្មើ។

បន្ទាប់ពីពេលនោះមក ជាអាណាចក្រនៃទ្រឹស្តីបង្ការនិងសង្ស័យ។ លីវប៉ាងនិងប្រពន្ធតែងយល់ថា បើទោះជាហានស៊ីងមិនបានបះបោរខ្លួនឯងក៏ដោយ សូម្បីតែការផ្តល់ដំបូន្មានជាយុទ្ធសាស្ត្រដល់អ្នកបះបោរ ដែលប៉ុនប៉ងបះបោរក៏នឹងគំរាមដល់រាជវង្ស។ ដូច្នេះហើយការសម្លាប់ Han Xin បានក្លាយជាជម្រើសដ៏ល្អបំផុតសម្រាប់លីវប៉ាងនិងលូហ្ស៊ី។

លីវប៉ាងបានដឹងពីការគំរាមកំហែងនេះ ប៉ុន្តែមានការស្ទាក់ស្ទើរក្នុងការបញ្ចេញសកម្មភាព ព្រោះខ្លាចថា អាចនឹងមានសង្គ្រាមស៊ីវិលមួយទៀតដូច្នេះ Lu Zhi បានសម្រេចចិត្តធ្វើសកម្មភាពដោយខ្លួនឯង ខណៈពេលដែល Liu Bang កំពុងធ្វើជាប់ដៃប្រយុទ្ធប្រឆាំងនឹងការបះបោរនៅឆ្ងាយ។ នាងបានផ្ញើពាក្យទៅ Han Xin ថាអធិរាជបានបង្ក្រាបការបះបោរហើយចង់ចួបលោក។

ឧបាយកលនេះបានទាក់ទាញមេទ័ពហានស៊ីងដើរចូលក្នុងវាំងដើម្បីអបអរជ័យជម្នះ។ នៅពេលនោះ Lu Zhi បានចាប់ខ្លួនហាន ស៊ីនដោយអន្ទាក់ បន្ទាប់មកចោទប្រកាន់គាត់ពីបទសហការជាមួយពួកឧទ្ទាម។

Han Xin ត្រូវបានគេចាត់ទុកជាជនក្បត់ដោយត្រូវកាត់ក្បាល សាកសពយកទៅដាក់តាំងនៅទីលានផ្សារ។ នៅពេលដែល Liu Bang ត្រលប់មករាជធានីវិញ ក៏សម្តែងការសោកស្តាយចំពោះការស្លាប់របស់មេទ័ពដ៏ក្លាហាន ប៉ុន្តែនៅពេលជាមួយគ្នានោះ គាត់ពេញចិត្តចំពោះវិធីដែលអធិរាជនីបានជួយដោះស្រាយការគំរាមកំហែងដ៏មានសក្តានុពលចំពោះនគរ។

ដោយសារស្អប់ថា ហានស៊ីងជាមន្ត្រីដែលក្រអឺតក្រទមនិងខ្លាំងពូកែហួស នាងលូហ្សឺ បានសម្លាប់ហានស៊ីងដោយការប្រមាថ គឺចាប់ចងគាត់ និងឱ្យស្រីៗអ្នកបម្រើសម្លាប់មេទ័ពម្នាក់នេះ ម្តងបន្តិចទម្រាំស្លាប់។

មិនតែប៉ុណ្ណោះបានដាក់បញ្ជាឱ្យសម្លាប់សម្អាតគ្រួសាររបស់ហានស៊ីងទាំងមូលផង។ ជាមួយប៉េងយូអ៊ីក៏ដូចគ្នា។ លូហ្សឺបានធ្វើពុតជាអត់ទោសឱ្យព្រោះគុណសម្បត្តិប៉េងយូអ៊ី ធ្លាប់ជួយគ្រួសារនេះទម្រាំឈ្នះសង្គ្រាមបានរាជ្យ ដូច្នេះប្រជារាស្ត្រទាហាននានាអាចវាយតម្លៃ ។ ដំបូងនាងធ្វើជាបញ្ជាឱ្យនិរទេសទៅព្រំដែន ប៉ុន្តែពីក្រោយ បានចាត់ឃាតករសម្លាប់តាមផ្លូវយកក្បាលមកបង្ហាញខ្លួនវិញ។

មិនតែប៉ុណ្ណោះ រាជនីលូក៏បានជីកស្មៅទាំងឫសលើគ្រួសារប៉េង គឺសម្លាប់៩ពូជ អ្នកបម្រើម្នាក់ក៏មិនឱ្យសល់។

នៅពេលមករាជវាំងហានដំបូង រាជនីលូហ្សឺក៏មិនអាចស្វែងរកឱកាសដើម្បីតទល់ជាមួយស្នំឯកឈី ដែលជាម្ចាស់បំណុលស្នេហ៍ ព្រោះស្នំនេះនៅតែជាទីសព្វព្រះទ័យខ្លាំងដោយលីវប៉ាង។

រាជនីលូ ត្រូវទ្រាំលេបគំនុំ រហូតដល់ការស្លាប់របស់ស្វាមី ហើយកូនប្រុសធំរបស់ខ្លួន គឺលីវ យីងបានឡើងគ្រងរាជសិន។ ធម្មតា លីវយីងមានភាពទន់ខ្សោយនិងមានចិត្តធម៌ណាស់  មុនពេលលីវប៉ាងស្លាប់តែងតែរិះគិតបារម្ភថាកូនប្រុសនេះមិនអាចនឹងសោយរាជ្យរក្សានគរបានល្អទេ។

លីវប៉ាងតែងតែចង់បណ្តុះបណ្តាល លី រូយី ដែលជាកូនប្អូនជាង នេះជាភ្លើងបន្ទុបក្នុងទ្រូងរាជនីលូ។ រាជនីលូមានបទពិសោធន៍សង្គ្រាមនិងបញ្ញា  ថែមទាំងយកចិត្តបាននូវមនុស្សខ្លាំងៗជុំវិញលីវប៉ាង។

នាងបានរៀបចំកម្លាំង ដែលគាំទ្រឱ្យកូនខ្លួននៅតែបានសិទ្ធិជារាជទាយាទ ទោះណាជាលីវយីងខ្សោយនិងចិត្តទន់។ ម្ល៉ោះហើយ នៅនឹងមុខមន្ត្រីនានា លីវប៉ាងមិនអាចដកហូតអំណាចបន្តរាជពីកូនប្រុសរបស់ប្រពន្ធដើមបានទេ។ ទ្រង់ក៏ចាត់បញ្ជូនរូយី អាយុ១២ឆ្នាំទៅគ្រប់គ្រងតំបន់មួយផ្សេងចំណែកម្តាយគេ គឺស្នំឯកឈី នៅឆាងអានជាមួយលីវប៉ាងដល់ថ្ងៃទ្រង់សុគត។

នៅឆ្នាំ១៩៥ មុនគ.ស អធិរាជ Gaozu ហៅលីវប៉ាង បានសោយទិវង្គតហើយត្រូវបានស្នងរាជ្យបន្តដោយ ព្រះទាយាទ Liu Yng ដែលត្រូវបានគេស្គាល់តាមប្រវត្តិសាស្ត្រថា ជាអធិរាជ Hui នៃ Han កូនប្រុសរបស់រាជនី Lü Zhi ។ ម្តាយក៏ត្រូវបានអធិរាជ Hui ប្រទានកិត្តិនាមជាជាអធិរាជនីលូ។ ដោយអំណាចនិងឥទ្ធិពលពេលនេះ ជារដូកាលដែលរាជនីលូផ្តើមបង្ហាញភាពឆ្កួតលេលាចេញដោយ

ចំហ ហើយរកឱកាសសម្លាប់ស្នំឈីដែលជាម្តាយចុងស្តេចនិងប្អូនចុងអាយុ១២ឆ្នាំរបស់គេ គឺលីវ រូយី ។

ទោះយ៉ាងណា រាជនីLü Zhi មិនបានធ្វើបាបម្ចាស់ក្សត្រីដទៃទៀតរបស់លីវប៉ាង(អធិរាជGaozu) ឱ្យតែពួកគេសម្របខ្លួនប្រព្រឹត្តិទៅតាមច្បាប់និងទំនៀមទម្លាប់របស់គ្រួសារអធិរាជបានល្អ លើកលែងស្នំឯកឈី ដែល Lü Zhi គុំគួនយ៉ាងខ្លាំងដោយសារតែជម្លោះលើការប៉ុនប៉ងចែករាជកាលពីប្តីនៅរស់ រវាងកូនខ្លួនលីងយីងនិងកូនស្នំឈី Liu Ruyi ដែលជាព្រះអង្គម្ចាស់ Zhao។

ដំបូងការដាក់ទោស គឺសំដៅលើស្នំ Qi ដោយបានប្រកាសដកតំណែងនិងចាត់ទុកស្នំសំណព្វរបស់លីវប៉ាងដូចជាទណ្ឌិត កោរសក់និងស្លៀកពាក់ស្តើង រស់នៅក្នុងគុកត្រជាក់ ថែមបង្ខំឱ្យធ្វើការងារធ្ងន់នៅរោងម៉ាស៊ីនកិនស្រូវ។

បន្ទាប់មក Lü Zhi បានកោះហៅ រាជបុត្រ Liu Ruyi ដែលមានអាយុប្រហែល ១២ ឆ្នាំមកឆាងអាន ដោយមានបំណងសម្លាប់រួមគ្នាជាមួយម្តាយ។

ទោះបីជាយ៉ាងណាក៏ដោយមន្ត្រីម្នាក់ឈ្មោះ Zhou Chang (周昌) ដែលជាអធិការបតីនៅតំបន់ដែលលីវប៉ាងបញ្ជូន Liu Ruyi ទៅតែងតែការពារ។ មន្ត្រីនោះជាមនុស្សដែល រាជនីLü Zhi គោរពព្រោះគាត់ឈរខាងនាង និងបានជួយជំរុញឱ្យកូនប្រុសនាងបានឡើងសោយរាជ្យ។

ដំបូងលោក Zhou Chang (周昌) បានការពាររាជបុត្រ Liu Ruyi ជាបណ្តោះអាសន្នពីគ្រោះថ្នាក់ដោយឆ្លើយតបទៅនឹងបញ្ជារបស់រាជនី Lü ថា ព្រះអង្គម្ចាស់ Zhao មានជំងឺក្តៅ មិនសក្តិសមក្នុងការធ្វើដំណើរក្នុងផ្លូវឆ្ងាយឡើយ។

ក្រោយមក ប្រើវិធីដដែលនេះទៀត រាជនីលូក៏បញ្ជាឱ្យ Zhou Chang មករាជធានី ហើយចាប់ឃុំខ្លួនទើបអាចកោះហៅរាជបុត្រ Liu Ruyi មករាំងឆាងអាន។

បានដំណឹងនេះកាលណា អធិរាជ Hui បានព្យាយាមជួយសង្គ្រោះប្អូនចុង Liu Ruyi នេះដោយស្ទាក់ចាប់មិនឱ្យចូលគាល់នឹងឆ្លើយតបមាតាថា ទ្រង់ត្រូវការឱ្យប្អូនចុងនៅក្បែរគ្រប់ពេលវេលាជួយរាជកិច្ច។ ដូច្នេះ រាជនី Lu Zhi បានសំងំមិនសកម្មភាពអស់រយៈពេលជាច្រើនខែ។

អធិរាជ លីវយីង (Hui) នៃ Han មានការទើសរង្គាសជាខ្លាំងនឹងរឿងនេះ ទ្រង់មិននឹកស្មានថាមាតាប្រែជាឃោរឃៅខ្លាំង ដែលខុសពីអតីតមាតារបស់ទ្រង់កាលពីមុន។

កិច្ចការពារប្អូនប្រុសនេះ ដំណើរការបានប៉ុន្មានខែដោយស្ងប់សុខ ប៉ុន្តែនៅពេលព្រឹកមួយព្រះរាជាត្រូវចេញបរបាញ់អធិរាជដែលតែងតែនាំ Liu Ruyi ទៅជាមួយគ្រប់ទីកន្លែងដែលគាត់ទៅបែរជាខកខាន ដោយសារទ្រង់ក្រោកមិនទាន់ពីព្រលឹម។

ណាមួយ ព្រះចៅអធិរាជសន្មតថា មាតារបស់ទ្រង់នឹងមិនរៀបចំផែនការប្រឆាំងនឹងរាជបុត្រ Zhaoទៀតនោះទេ ខណៈដែលជាច្រើនខែបានកន្លងផុតទៅ ហាក់មិនមានអ្វីកើតឡើង។

ទោះជាយ៉ាងណាក៏ដោយបានឱកាសនេះកាលណា ព្រះរាជនីលូបានបញ្ជាកម្លាំងធ្វើឃាតមកបង្ហាញខ្លួន ចាប់ស្តេចប្អូន បំពុលដល់ស្លាប់។

នៅពេលដែលអធិរាជត្រលប់មកវិញ Liu Ruyi បានស្លាប់ទៅហើយ។

ថ្ងៃនោះរាជនីលូសប្បាយចិត្តណាស់ បានទៅដល់គុកនៃស្នំឈីហើយប្រាប់ថា«កូនប្រុសឯងបានស្លាប់ហើយ!»។

ស្នំឯកឈីយំសង្រេង ហើយស្រែកថាឱ្យសម្លាប់នាងតែម្តងទៅ។ បន្ទាប់មក រាជនីលូតបថាទោសឯងមិនមែនស្រាលយ៉ាងនេះទេ។ ទ្រង់ក៏បញ្ជាឱ្យពួកឆ្មាំកាត់អវយវៈ ដៃជើងរបស់ស្នំឈី ចាក់ឆ្កៀលយកភ្នែក កាត់អណ្តាត កាត់ច្រមុះខ្លីដូចជ្រូក កាត់ត្រចៀក និងដាក់ចោលទៅក្នុងទ្រុងជ្រូក បោះទៅក្នុងបង្គន់ ហើយហៅនាមថា«ជ្រូកមនុស្ស» (人彘)។

មិនតែប៉ុណ្ណោះ រាជនីកំណាចបានប្រាប់ពេទ្យឱ្យប្រើថ្នាំដែលមិនឱ្យនាងឈីអាចស្លាប់បានងាយដើម្បីឱ្យរងការឈឺចាប់យូរ។ បន្ទាប់មកបានបង្ខំមន្ត្រីរាជការនិងឧត្តមសេនីយ៍ទាំងអស់ ឱ្យមកមើលឃើញការរងទុក្ខរបស់ស្នំឈី ដែលត្រូវបានទុកចោលក្នុងបន្ទប់បង្គន់ ដែលពោរពេញដោយក្លិនស្អុយ។ ស្ត្រីរងគ្រោះនៅរស់អស់រយៈពេលបីថ្ងៃ មុនពេលនាងដាច់ខ្យល់។ រាជនីលូចង់យករូបភាពនេះ បន្លាចឱ្យគ្រប់គ្នាខ្លាចអំពើឆ្កួតលេលារបស់នាង លែងហ៊ានបះបោរប្រឆាំងនឹងនាង។

ក្រោយមក ទ្រង់ថែមបានអញ្ជើញព្រះចៅអធិរាជ មកទតជ្រូកមនុស្សផងដែរដោយបានប្រាប់ថា «នេះឯង ស្រីដែលពង្វក់ឪពុកអ្នក!»។

ព្រះចៅអធិរាជ Xiaohui បានឃើញ «ជ្រូកមនុស្ស» កាលណាស្លុតជាពន់ពេក និងទម្រាំដឹងថា «ជ្រូកមនុស្ស» ជានរណា អធិរាជទ្រង់ឈឺចិត្តនឹងភាពឃោរឃៅរបស់មាតាទ្រង់ រហូតទ្រង់ធ្លាក់ខ្លួនឈឺជាទម្ងន់។

គំនិតដំបូង របស់ Lu Zhi គឺចង់ពង្រឹងចិត្តយុវជនឱ្យរឹងមាំ ផ្ដាច់ការលើតួនាទីជាអធិរាជ ប៉ុន្តែព្រះចៅអធិរាជដែលមានព្រះជន្ម១៧ វស្សាបែរជាឃើញហើយមានរបួសចិត្តយ៉ាងតក់ស្លុតចំពោះអំពើឃោរឃៅដ៏សោកសៅដែលម្ដាយខ្លួនប្រព្រឹត្ត។ ព្រះចៅអធិរាជវ័យក្មេង ដែលមានបុគ្គលិកលក្ខណៈយកចិត្តទុកដាក់លើមនុស្សធម៌ ក្រោយពីទតមើលរូបកាយរងទារុណកម្មរបស់ស្នំឈីបានខ្ទេចខ្ទាំចិត្ត។

ទ្រុងញាប់ញ័រនឹងមានអារម្មណ៍ធុញថប់ អស់សង្ឃឹម។ ព្រោះក្រមសីលធម៌ខុងជឺមិនយល់ស្របចំពោះការមិនស្ដាប់បង្គាប់ឪពុកម្ដាយរបស់ខ្លួនឡើយ អធិរាជមិនអាចដាក់ទោសរាជនីលូបាន ក៏បានជ្រើសផ្លូវឃ្លាតឆ្ងាយពីម្ដាយ លែងទាក់ទងនិងបានប្រកាសដកតំណែងជា Dowager Empress ជាម្ដាយស្ដេច។

លូហ្ស៊ី មានការភ្ញាក់ផ្អើលចំពោះប្រតិកម្មដ៏ដាច់ចិត្តរបស់កូនប្រុសតែមួយគត់របស់នាង ហើយគិតថា គ្រប់យ៉ាងជាការខិតខំរបស់នាង យុវជនរូបនេះមិនបានដឹងគុណ។ កូនប្រុសមិនព្រមចួបម្ដាយរាប់ឆ្នាំរហូតដល់ស្លាប់។

មុននោះបន្តិច អធិរាជបានបោះបង់ចោលអំណាចនិងរាជកិច្ចរបស់ទ្រង់ទាំងស្រុង ដោយសោយសុខនិងស្រីស្រា ព្រោះមិនអាចការពារម្ដាយចុងតាមបណ្ដាំឪពុកដែលបណ្ដោយឱ្យស្នំ Qi និងកូនប្រុសរបស់នាងបានស្លាប់នៅឆ្នាំដំបូងនៃរជ្ជកាលរបស់អធិរាជ Hui នេះ។

អ្នកប្រវត្តិសាស្ត្របានកត់ត្រាសម្ដីអធិរាជដែលនិយាយទៅកាន់ម្ដាយថា «នេះមិនមែនជាទង្វើមនុស្សទេ! ក្នុងនាមជាបុត្ររបស់ព្រះចៅអធិរាជលីវប៉ាង ខ្ញុំនឹងមិនអាចគ្រប់គ្រងអាណាចក្រនេះបានឡើយដែលបណ្ដោយឱ្យមានរឿងបែបនេះកើតឡើង!»។

មនុស្សខ្លះសរសេរថា ស្នាដៃរបស់រាជនីលូ គឺឃោរឃៅ ប៉ុន្តែគ្មានអ្នកណាបានយល់ពីអារម្មណ៍ប្រពន្ធដើមម្នាក់ដែលត្រូវស្វាមីមិនរវីរវល់ពេលត្រូវគេចាប់បង្ខំជាមួយកូន បន្ទាបបន្ថោកធ្វើជាចំណាប់ខ្មាំងអស់រយៈពេលជាច្រើនឆ្នាំនៅនគរឈូ ខណៈពេលដែលប្រពន្ធចុងឈ្មោះ Qi បានរីករាយនឹងជីវិតក្បែរលីវប៉ាង រស់ក្នុងបន្ទប់ថ្លៃថ្នូរដូចហង្ស មានគេបម្រើឆ្វេងស្ដាំ។

ចាប់ពីពេលមាននាងឈី លីវប៉ាងតែងឱ្យនាងរស់នៅស្រួល ច្រៀងរាំក្នុងដៃប្ដី ទុករាជនីលូនិងកូនៗចោល។ ជាឱកាសឱ្យប្រពន្ធចុងបាននិយាយបង្កាច់បង្ខូចធ្វើទុក្ខប្រពន្ធដើមជាច្រើនសា។ អ្នកខ្លះបានកាន់ជើងថា រាជនីលូបានគ្រប់គ្រងកូនៗរបស់នាង ប្ដីមិនដែលនៅផ្ទះ ព្រោះរត់លុនធ្វើសង្គ្រាមនាងទទួលកិច្ចការបម្រើគ្រួសារប្ដី ភ្ជួរដី ធ្វើស្រែ ទាំងនាងជាកូនស្រីអ្នកមានមិនធ្លាប់លំបាក។

នាងបានសូកប៉ាន់អាហារ និងសម្លៀកបំពាក់ដល់ពួកឆ្មាំដើម្បីចិញ្ចឹមពេល Liu Bang មិននៅ។ល។ ទីបំផុតប្តីឈ្នះសង្គ្រាម មានរាជបល្ល័ង្កគ្រួសារអាចជួបជុំគ្នាវិញបាន ប៉ុន្តែប្តីនាងដាក់ដៃជុំវិញតែប្រពន្ធចុង មិនមើលមុខប្រពន្ធកូនមុន។ លីវប៉ាងនិងឈី តែងតែល្អកល្អឺនក្នុងព្រៃឫស្សីដូចលលកញីឈ្មោលសោយសុខស្នេហាជាមួយបទភ្លេងនិងការរាំច្រៀងភ្លើតភ្លើន។

រឿងទាំងនេះរាជនីលូនៅអាចទ្រាំទ្របាន ប៉ុន្តែអ្វីដែលនាងមិនអាចបំភ្លេចនោះគឺថាស្នំឯកQi ថែមទាំងចង់ដណ្តើមយកតំណែងរាជទាយាទឱ្យទៅកូនប្រុសខ្លួនទៀត។

ស្រីស្នំឈី ជាទីពេញចិត្តរបស់ស្តេច តែនាងមានមហិច្ឆតាខ្លាំងហើយល្ងង់ នាងចេះតែច្រៀងរាំតែមិនចេះធ្វើមិត្តជាមួយមន្ត្រីចាស់ៗដើម្បីបណ្តុះអំណាចឱ្យកូន។ ដូច្នេះមានពាក្យចិនមួយគេនិយាយឱ្យនាងថា «អ្វីដែលគួរឱ្យអាណិត មិនមែនរឿងល្ងង់ តែជាមនុស្សដែលល្ងង់ហើយមានមហិច្ឆតាលើសលប់ពេក!»។ ប្រសិនបើស្នំឯក Qi គិតចង់បានឱ្យកូនខ្លួនឡើងជំនួសកូនដើម នាងគួរតែរៀបចំខ្លួនមុនពេលមរណភាពរបស់ Liu Bang ប៉ុន្តែលោកស្រី Qi មិនបានធ្វើ អ្វីទាំងអស់ក្រៅតែពង្វក់ស្តេច និងពីបញ្ជូនកូនប្រុសគឺ Liu Ruyi ទៅរៀនសូត្រជាមួយមន្ត្រីច្បាប់។ នាងមិនបានរៀបចំផ្លូវក្រោយសម្រាប់ខ្លួននាងទេ នៅពេលផ្លូវមុខត្រូវដកចេញនាងបានបាត់បង់ឱកាសរត់ទាំងស្រុង ព្រោះនាងមិនយល់ពីការប្រយុទ្ធខាងនយោបាយ។

មិនយូរប៉ុន្មានទេ ក្រោយស្អប់ភាពឃោរឃៅរបស់ម្តាយ ស្តេចលីវយីងបានឈឺស្លាប់ក្នុងវ័យ២៣ឆ្នាំ។ ការស្លាប់នេះមិនបានធ្វើឱ្យរាជនី Lu Zhi ស្រក់ទឹកភ្នែកមួយតំណក់ទេ។

មរណភាពនេះ ជាមូលហេតុដែលអធិរាជនីលូ បានក្លាយជាស្ត្រីដំបូងគេក្នុងប្រវត្តិសាស្ត្រ ដែលត្រូវបានគេហៅថា អធិរាជនី គឺនាងកាន់អំណាចខ្លួននាងតែម្តង។

មន្ត្រីខ្លះបានសរសេរទុកថា បន្ទាប់ពីការស្លាប់របស់កូនប្រុសតែមួយគត់ ទ្រង់មិនបានស្រក់ទឹកភ្នែកទេ តើអធិរាជនីលូពេលនេះជានរណា? នាងបានស្លាប់បាត់ជាមួយការឈឺចាប់ពីអតីតកាលនិងបានក្លាយជាបិសាចគ្មានឈាម?

នាងច្បាស់ជានឹងមិនមានអារម្មណ៍សាមញ្ញៗដូចមនុស្សធម្មតាទៀតនោះទេ។ មុនពេលមរណភាពរបស់ខ្លួន លីវប៉ាងដែលជាបុព្វបុរសដ៏អស្ចារ្យនៃរាជវង្សហាន បានរៀបចំមន្ត្រី Chen Ping និង Zhou Bo ក៏ដូចជាមន្ត្រីសំខាន់ៗផ្សេងទៀត សម្រាប់គាំទ្រជុំវិញរាជទាយាទ Liu Ying ជួយកូនប្រុស

របស់ខ្លួន និងធានាស្ថេរភាពនៃគ្រួសារ Han ប៉ុន្តែមើលស៊ីជម្រៅ គាត់បានដឹងពីចេតនារបស់រាជនី លូ ដែលអាចមានលទ្ធភាពដណ្តើមអំណាចនាពេលអនាគត។

អ្នកខ្លះសួរថា ក្នុងនាមជាម្តាយ តើនាងនឹងលួចប្លន់បល្ល័ង្ករបស់កូនប្រុសខ្លួនឬទេ? នៅចំពោះមុខអំណាចកំពូលអធិរាជជាច្រើននៅសឹងគ្រប់ខ្សែរាជវង្ស អាចទាំងសម្លាប់ឪពុកដើម្បីដណ្តើមរាជបល្ល័ង្ក ផងដើម្បីបន្តទុកអំណាចឱ្យកូនៗជំនាន់ក្រោយខ្លួន ចុះលូដណ្តើមអំណាចពីកូន?

ប្រវត្តិសរសេរថា នាងមិនសម្លាប់កូនប្រុសរបស់នាងឡើយ ប៉ុន្តែនាងនឹងធ្វើឱ្យគេចាកចេញដោយប្រយោល ហើយទុកគ្រប់យ៉ាងឱ្យគ្រួសារ Lu របស់នាងវិញ។ នេះជាអ្វីដែលនាងពិតជាបានធ្វើ។ មិនមែនស្នំឈី ចេះតែចង់បានទេ តែទាំងនេះជាអ្វីដែលលីវប៉ាង ដឹងជាសម្ងាត់។ លីវប៉ាងដឹងពីមហិច្ឆតាប្រពន្ធដើម ហើយមើលឃើញថាកូនខ្លួន គឺរាជទាយាទ Liu Ying ជាមនុស្សទន់ខ្សោយ គ្មានសមត្ថភាពដោះស្រាយជាមួយអធិរាជជាម្តាយបន្តិចណាទេ បានជាចង់បានស្តេចផ្សេងដែលរឹងមាំជាង អាចទប់ទល់ជាមួយគ្រួសារលូ។

ប៉ុន្តែនៅបន្ទាប់ពីការសោយទីវង្គតរបស់ទ្រង់ Liu Ying បានឡើងសោយរាជ្យដោយជោគជ័យ។ ដោយប្រឈមនឹងការភ័យខ្លាចចំពោះភាពឃោរឃៅរបស់ម្តាយ កូនប្រុសបានបាក់ស្បាតស្លាប់ ហើយរាជនីលូ បានក្លាយជាអ្នកគ្រប់គ្រងរាជវង្សហាន ដូច្នេះអ្នកវាយតម្លៃបានសរសេរថា នាងបានសម្លាប់លោកស្រី Qi និង Liu Ruyi ដើម្បីបញ្ចេញការព្រមានដ៏សែនអាអាក្រក់ដើម្បីសម្លាប់ Liu Ying ដោយប្រយោល។

នេះដោយសារតែរាជនីលូ ដឹងថា Liu Ying មានចិត្តល្អពេក ហើយមានសមត្ថភាពផ្លូវចិត្តទាប ដូច្នេះបន្ទាប់ពីបានឃើញស្នំQi ដែលត្រូវបានម្តាយប្រែទៅ«មនុស្សជ្រូក» Liu Ying មិនអាចទ្រាំមិនញាប់ញ័រសន្ធត់និងធ្លាក់ឈឺបានទេ ហើយទីបំផុតបានទទួលមរណភាពនៅអាយុ២៣ឆ្នាំ។

សម្រាប់រាជនីលូ ការសោយទិវង្គតរបស់កូនប្រុសមិនបានធ្វើឱ្យប៉ះពាល់ដល់អំណាចនាងទេ។ ម្យ៉ាងវិញទៀត ដោយសារតែនាងមានអំណាចនៅក្នុងដៃរបស់នាងរួចហើយ ការស្លាប់របស់កូនប្រុសនាងបានធ្វើឱ្យតំណែងរបស់នាងកាន់តែមានស្ថេរភាពនិងឯករាជ្យ។

បន្ទាប់ពីនោះមក បណ្តាមន្ត្រីស្មោះរបស់លីវប៉ាង ដែលត្រូវបានចាត់ឱ្យនៅថៃមើលគ្រួសារលីវដូចជា ចេនពីង Chen Ping និង វ៉ាង លីងWang Ling ជាដើម បានបាត់បង់ជញ្ជាំងផ្អែក នេះជាពេលដែលនាងអាចសើចហើយ ម៉េចក៏នាងយំទៅរួច។

ការកត់ត្រានិយាយថា មហាតលិកម្នាក់ឈ្មោះ Cao Can ដែលជាមន្ត្រីមហាតលិកជាន់ខ្ពស់របស់ព្រះរាជា មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលបានឃើញរូបរាងធម្មតារបស់ Empress Lu ពេលកូនគាត់ស្លាប់។ នាងមានអាការៈព្រងើយកណ្តើយដែលពីដំបូងគេគិតថា រាជនីឈឺចាប់ឡើងឆ្កួត តែតាមពិតមិនមែនឡើយ គ្រប់យ៉ាងបានដំណើរការតាមគម្រោងរយៈពេលវែងនៃគ្រួសារនាង គឺត្រកូលលូ។

គួររំឭកដែរថា មុនពេលកូនប្រុសនាងស្លាប់ នាងមិនមែនមិនដឹងឡើយថា គេទន់ខ្សោយនិងមិនអាចកាន់អំណាចបានរឹងមាំយូរអង្វែង។

ដូច្នេះ រាជនីលូនិងបក្សពួកបានបង្កើតជាគម្រោងការវែងឆ្ងាយ។ រាជនីលូ បានជ្រើសយកក្មួយស្រីត្រកូលខ្លួនជាច្រើននាក់មកធ្វើជាកូនស្រីធម៌ ហើយដាក់ឱ្យរៀបការជាមួយកូនប្រុសទាំងអស់របស់លីវប៉ាង មិនថាកូននាងផ្ទាល់លីវយីងដែលជាអធិរាជ ថែមទាំងកូននៃស្នំផ្សេងៗ។

នៅឆ្នាំ១៩១ មុនគ្រឹស្តសករាជ មិនយូរក្រោយលីវយីង ឡើងកាន់អំណាចជាព្រះចៅអធិរាជ រាជនីលូបានបង្ខំរៀបអាពាហ៍ពិពាហ៍អធិរាជ លីវយីង ជាមួយក្មួយស្រីបង្កើតរបស់គេ ដែលជាកូននៃរបស់កូនស្រីច្បងលីវប៉ាងព្រះនាង Yaun គឺនាងឈ្មោះ Zhang Yan ដែលទើប១២ឆ្នាំ។

ពួកគេមិនមានកូនទេ ព្រោះព្រះចៅអធិរាជមិនផ្សំដំណេក។ ក្នុងសំណេរកត់ត្រា រាជនីលូបានប្រាប់កូនស្រីធម៌ Zhang Yan ឱ្យរកក្មេងប្រុសប្រាំបីនាក់មកចិញ្ចឹមដោយសម្លាប់ម្តាយបង្កើតរបស់ពួកគេចោលទាំងអស់។

មានភាពមិនច្បាស់លាស់ថាតើកុមារទាំងនេះជាកូនរបស់អធិរាជ Hui? ទស្សនៈបែបប្រពៃណីគឺថាពួកគេមិនមែនទេ ខណៈពេលដែលអ្នកប្រវត្តិសាស្ត្រសម័យទំនើបជឿថាពួកគេបានកើតមកជាប្រពន្ធចុងរបស់គាត់។

ដំណើរការនេះ បាននាំដល់ការព្យាបាទកូនប្រុសផ្សេងទៀតរបស់អធិរាជលីវប៉ាងអាចធ្វើទៅបាន។ ឧទាហរណ៍នៅរដូវរងាឆ្នាំ ១៩៥ឬ១៩៤ មុនគ.ស ព្រះអង្គម្ចាស់ Liu Fei មានងារជាព្រះអង្គម្ចាស់ Qi កូនប្រុសច្បងរបស់អធិរាជលីវប៉ាង ដែលកើតពី Lady Cao (曹氏) បានទៅលេង វាំង Chang'an ហើយព្រះអង្គនិងអធិរាជ Hui (លីវយីង)បានជប់លៀងជុំបងប្អូន។

នៅទីនោះ រាជនីលូក៏ចូលរួម។ កំពុងស្ថិតក្នុងការហូបចុក ព្រះចៅអធិរាជ Hui បានផ្តល់កិត្តិយសដល់ Liu Fei ទុកថា ជាបងប្រុសធំ ហើយបានបញ្ជាឱ្យគ្រប់គ្នាទុកឱនលំទោនដោយគោរព រឿងនេះធ្វើឱ្យ Lu Zhi ជាម្តាយច្រណែនអន់ចិត្ត។

រាជនីលូ បានណែនាំអ្នកបម្រើផ្ទាល់របស់នាងចាក់ស្រាពុលមួយពែងឱ្យរាជបុត្រ Liu Fei ហើយបន្ទាប់មកជូនទៅគាត់ឱ្យក្រេប។

Liu Fei ហៀបនឹងផឹកស្រានោះ ត្រូវអធិរាជ Hui ដែលបានដឹងរឿងឃោរឃៅនៃម្តាយខ្លួន បានលូកទៅចាប់យកពែងរបស់Liu Fei ធ្វើហាក់ដូចជាចង់ផឹកជំនួស។

ពេលនោះ រាជនីលូបានក្រោកមកភ្លាមៗ គោះពែងចេញពីដៃរបស់អធិរាជ Hui កំពប់ចោលស្រាពិស។ បន្ទាប់មក Liu Fei បានដឹងថាខ្លួនកំពុងត្រូវបានយាយី។ ដើម្បីយករួចជីវិតចាកចេញ រាជបុត្រនេះបានស្ម័គ្របោះបង់ការបញ្ជាការទ័ពទាំងមូល ឱ្យកូនស្រីរបស់ធម៌របស់រាជនីលូគឺព្រះនាង Yuan នៃត្រកូល Lu ។ រាជនីលូបានទទួលយកការផ្តល់ជូននេះ ហើយអនុញ្ញាតឱ្យលីវ ហ្វេយ ចាកចេញដោយសុវត្ថិភាព។ មិនយូរទេ លូបានបង្ខំឱ្យកូនប្រុសខ្លួនរៀបការនឹងកូនស្រីធម៌ គឺព្រះនាង Yuan នោះ។

បន្ទាប់ពីនោះ រាជនីLü Zhi ក៏បានដើរតួសំខាន់ ក្នុងការស្លាប់របស់កូនប្រុសលីវប៉ាង ម្នាក់ជាមួយស្នំផ្សេង ទៀតគឺ Liu You ដោយបង្ខំ ឱ្យLiu You រៀបការជាមួយក្មួយស្រីរបស់ខ្លួនឈ្មោះ Lü Zhi។ ពេលលីវយូ មានទំនាក់ទំនងស្នេហាជាមួយនារីម្នាក់ទៀត ក្មួយស្រីរបស់ Lü Zhi បានរាយការណ៍ទៅមីងរបស់នាងថា Liu You កំពុងរៀបចំការបះបោរ។ រាជនីLu Zhi បានកោះហៅ Liu You មកកាន់ Chang'an ហើយឱ្យដាក់គុកនិងបង្អត់អាហារដល់ស្លាប់។ បន្ទាប់មករាជនីលូ បានកូននៃស្នំម្នាក់ទៀតឈ្មោះលីវហ៊ុយ ឱ្យរៀបការជាមួយកូនស្រីរបស់ Lü Chan ជាខ្សែត្រកូល Lü របស់នាងដើម្បីតាមត្រួតពិនិត្យរាល់សកម្មភពរបស់ Liu Hui ដូធ្វើឱ្យ Liu Hui មានអារម្មណ៍ថា ជីវិតគ្មានន័យនិងពេញដោយការរឹតត្បិត។ ព្រះនាងលូ ជាភរិយាស្មោះនឹងប្តី មិនបានធ្វើតាមម្តាយមីង ក៏ត្រូវបានបំពុលស្លាប់។ ផ្តើមចេញពីនោះ Liu Hui មានទុក្ខព្រួយ ក៏បានធ្វើអត្តឃាតដោយភ័យខ្លាចនៅខែកក្កដា ឆ្នាំ១៨១ មុនគ.ស។

ក្រោយមកបន្ទាប់ពីអធិរាជលីវយីងស្លាប់ មន្ត្រីចេនពីង Chen Ping បានចូលមករាជវាំងដើម្បីសុំគាល់មួយអធិរាជនីលូ និងជំរុញនាងឱ្យតែងតាំងអធិរាជថ្មីដោយរើសយកកូនម្នាក់ក្នុងចំណោមកូនប្រុសចិញ្ចឹមទាំង៨របស់ចៅនាងគឺ ព្រះនាង Zhang។

ដោយមិននឹកស្មានដល់ ពេលនោះទ្រង់បានឮមន្ត្រីចេនពីង ស្នើដំឡើងព្រះចៅអធិរាជថ្មីមកពីខាងគ្រួសារ Lu ដូចជា Lu Tai ឬ Lu Chan ដែលជាមេទ័ពស្រាប់។ រាជនីលូ សប្បាយចិត្តខ្លាំងដែលការលើកឡើងរបស់ Chen Ping បានធ្វើឱ្យអំណាចយោធាប្រទេសធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់គ្រួសារលូ ស្មើនឹងការផ្លាស់ប្តូរអំណាច ពីគ្រួសារលីវមកឱ្យគ្រួសារលូជាសម្ងាត់។

ការភ្ញាក់ផ្អើលធំមួយ គឺថាមន្ត្រីចេនពីងគឺជាអ្នកជំនិតរបស់លីវប៉ាង ជាទីប្រឹក្សដែលលីវប៉ាងប្តីនាងធ្លាប់ជឿទុកចិត្តបំផុត។ តាមពិតចេន ពីងគ្រាន់តែព្រមរុញទុកបណ្តោយទឹក តែបានរៀបចំជាសម្ងាត់ក្នុងការផ្តួលត្រកូលលូ។

ក្នុងនោះអធិរាជ Qianshao បានបន្តុបឡើងមក ប៉ុន្តែព្រះអយ្យកាលូ បានក្តាប់អំណាចពិតប្រាកដនិងគ្រប់គ្រងរដ្ឋាភិបាលចក្រពត្តិទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលអធិរាជ Qianshao បានដឹងការពិតថាខ្លួនជាកូនចិញ្ចឹម ហើយផ្ទុះគំនុំចង់សងសឹកជូនម្តាយបង្កើត។ នៅឆ្នាំ ១៨៤ មុនគ.ស អធិរាជក្មេងរូបនេះបានរៀបគម្រោងសងសឹកលើរាជនីលូ តែត្រូវបានចាញ់ដៃអធិរាជ Dowager Lü និងត្រូវបានចាប់បង្ខាំងដោយសម្ងាត់នៅក្នុងវាំង។ លូបានប្រកាសជាសាធារណៈថាអធិរាជក្មេងមានជម្ងឺធ្ងន់ធ្ងរនិងមិនអាចចួបនរណាបានឡើយ។ មួយរយៈក្រោយមក នាងបានប្រាប់ទៅមន្ត្រីនានាថា អធិរាជ Qianshao នៅតែវិកលចរិក ដូច្នេះនាងត្រូវទម្លាក់ពីរាជ្យនិងប្រហារជីវិត។

តំណែងនេះត្រូវបានឡើងជំនួសដោយប្អូនប្រុសចិញ្ចឹមម្នាក់ទៀតមានឈ្មោះថា Liu Hong ។

ជាលទ្ធផលពិត គឺរាជនីលូបានដើរតួជាអធិរាជលើរាជបល្ល័ង្កនិងដាក់នាមថ្មីឱ្យខ្លួនថា Zhen (ភាសាចិន៖ 朕; pinyin: Zhèn) ដែលជាសព្វនាមបុគ្គលអធិរាជទីមួយ បន្ទាប់ពីរាជវង្សឈើង។ រាល់ព្រះរាជបញ្ជារបស់នាង ត្រូវបានគេហៅថា Sheng Zhe (聖制) ដែលជាបទបញ្ជាផ្ទាល់នៃអធិរាជ។

ប្រវត្តិវិទូសាមញ្ញមិនចាត់ទុកថាអធិរាជ Qianshao ជាអធិបតេយ្យភាពពិតប្រាកដនោះទេ ដូច្នេះត្រូវបានដកចេញពីបញ្ជីអធិរាជក្នុងសាវតានៃរាជវង្សហាន។ ជាការបង្ការមុន លីវប៉ាងធ្លាប់បានចេញព្រះរាជក្រឹត្យថា គ្មានសមាជិកត្រកូលណាមួយ ដែលមិនមែនជាអធិរាជអាចក្លាយជាព្រះអង្គម្ចាស់

បានឡើយ មិនរាប់បញ្ចូលទាំងពូជស្តេចទៅរៀបការជាមួយវណ្ណៈអភិជនក្តី។ ទោះបីជាបែបនេះក្តីរាជនីលូបានព្យាយាមតំឡើងញាតិសន្តានរបស់នាងខ្លះឱ្យឡើងជាព្រះអង្គម្ចាស់។

អធិការបតីស្តាំ Wang Ling បានជំទាស់នឹងរឿងនេះ ប៉ុន្តែអធិការបតីឆ្វេង Chen Ping និងឧត្តមសេនីយ៍ Zhou Bo បានទទួលស្របធ្វើឱ្យ Wang Ling ស្តីបន្ទោស Chen Ping និង Zhou ថាប្រឆាំងនឹងច្បាប់មុននៃអធិរាជលីវប៉ាង( Gaozu)ដែលបញ្ជាឱ្យការពារអាណាចក្រ និងអំណាចនៃត្រកូល Liu ។ ដើម្បីយកចិត្តគាត់ រាជនីLü Zhi បានដំឡើងឋានៈមន្ត្រី Wang Ling ឱ្យកាន់តំណែងជា Grand Tutor (太傅) ប៉ុន្តែ Wang Ling  បានអះអាងថាគាត់ឈឺហើយបដិសេធ ដូច្នេះរាជនីបានបញ្ជាឱ្យគាត់ត្រលប់ទៅស្រុកកំណើតវិញដោយតែងតាំងចេនពីង Chen Ping ជាអធិការបតី។

បន្តទៀត នាង Lu Zhi បានបង្កើនល្បឿនបង្កើតក្រុមអភិជននិងមន្ត្រីស្និទ្ធ។

ជំហានដំបូងបន្ទាប់លូបានតំឡើងចៅប្រុសខាងម្តាយ ជាព្រះអង្គម្ចាស់ Lu ។ ប៉ុន្មានឆ្នាំក្រោយមកនាងបានតែងតាំងក្មួយប្រុស ជាច្រើននាក់ធ្វើជាព្រះអង្គម្ចាស់និងជាព្រះចៅអធិការ។ នៅក្នុងការផ្លាស់ប្តូរដែលមិនធ្លាប់មានពីមុនមក នៅឆ្នាំ១៨៤មុនគ្រឹស្តិករាជរាជនី Lü Zhi ក៏បានផ្តល់ងារជាប្អូនស្រីបង្កើតគឺនាង Lü Xu ជាស្តេចត្រាញ់នៃអាណាខេត្ត Lingguang។

# មរណភាព

អធិរាជនី Lü Zhi បានស្លាប់ដោយសារជំងឺនៅអាយុ៦១ ឆ្នាំក្នុងឆ្នាំ១៨០មុនគ្រឹស្តិករាជ ហើយត្រូវបានបញ្ចុះនៅក្នុងផ្នូរជាមួយអធិរាជលីវប៉ាង នៅឆាងលៀង(長陵)។

ទោះយ៉ាងណា នៅបន្ទាប់ពីការសោយទីវង្គតរបស់អធិរាជនីលូ នៅខែសីហាឆ្នាំ១៨០មុនគ.ស ចេនពីង និងចូវបូ បានសហការគ្នាដើម្បីបញ្ចប់ត្រកូលលូវិញ និងស្តារត្រកូលលីវឱ្យឡើងកាន់អំណាច ។

ការស្លាប់របស់រាជនី Lü Zhi បានញ៉ាំងឱ្យសមាជិកត្រកូលរបស់នាងទាំងអស់ ត្រូវបានទម្លាក់ចេញពីមុខអំណាច ថែមរងការសម្លាប់រង្គាលនៅក្នុងព្រឹត្តិការណ៍ធំមួយ ដែលត្រូវបានគេស្គាល់ជាប្រវត្តិសាស្ត្រថា Lü Clan Disturbance ការបំបាត់ត្រកូលលូ។

មេក្លោងនៃរដ្ឋប្រហារនេះ រួមមានរដ្ឋមន្ត្រីដែលធ្លាប់បម្រើអធិរាជ Gaozu ដូចជា Chen Ping, Zhou Bo និង Guan Ying រួចមានស្តេចថ្មី គឺរាជបុត្រ លីវហេង  Liu Heng កូនប្រុសរបស់លីវ ប៉ាង ជាមួយនារីសាមញ្ញមិនមែនអភិជន គឺស្នំបូ ឡើងគ្រងរាជ្យជាអធិរាជ Wen (សូមរង់ចាំអាន រាជបុត្រមហាហាន) ហើយនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៨០មុនគ.សទីប្រឹក្សាចេនពីង ត្រូវបានតែងតាំងជាអធិការបតីឆ្វេងរបស់អធិរាជ ចំណែកហ្ស៊ូបូ Zhou Bo ត្រូវបានតែងតាំងជាអធិការបតីស្តាំរបស់អធិរាជ Wen of Han។